ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៦០៧ អយក.ប្រក

# ប្រកាស

## ស្តីពី ការផ្តាច់សាលាឧបសម្ព័ន្ធ ធារាយណ៍ មកជាសាលាបឋមសិក្សាពេញលក្ខណៈ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត -១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកាឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិត លេខ ៨៤១ អយក .បម ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០២ របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ស្វាយរៀង**

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

### សំរេច

**ប្រការ១:** ផ្តាច់សាលាឧបសម្ព័ន្ធ **ធារាយណ៍** ពីសាលាបឋមសិក្សា **មេសថ្ងក** ដែលមានទីតាំងស្ថិតនៅភូមិ **ធារាយណ៍** ឃុំ **មេសថ្ងក** ស្រុក **ចន្ទ្រា** ខេត្ត **ស្វាយរៀង** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២:** សាលាបឋមសិក្សា **ធារាយណ៍** ត្រូវដឹកនាំដោយ នាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ស្វាយរៀង** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ចន្ទ្រា** នាយកសាលាបឋមសិក្សា **មេសថ្ងក** នាយកសាលាបឋមសិក្សា **ធារាយណ៍** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

រដ្ឋលេខាធិការ

**អ៊ឹម សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **ស្វាយរៀង**

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៥

-កាលប្បវត្តិ-ឯកសារ នា .បស